Updated March 14, 2022 Khmer

DOH 820-131

# ការណែនាំអំពីម៉ាស់អំឡុងពេលមានជំងឺ COVID-19

## ខ្លឹមសារសង្ខេបអំពីការកែប្រែនានានៅថ្ងៃទី 14 ខែមីនា ឆ្នាំ2022

- បានធ្វើបច្ចុប្បន្នភាពដើម្បីឱ្យស្របតាមការកែប្រែលើសេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងសេចក្តីប្រកាសរបស់អភិបាលរដ្ឋ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)

## សេចក្តីផ្តើម

នៅពេលអ្នកពាក់ម៉ាស់ អ្នកជួយការពារអ្នកដទៃនៅជុំវិញអ្នក ក៏ដូចជាខ្លួនអ្នកផងដែរ។ ឆ្លើយតបទៅនឹងជំងឺរាតត្បាតនេះ យើងបានដឹងថាមានពេលវេលា និងទីកន្លែងមួយចំនួនដែលការពាក់ម៉ាស់អាចកាត់បន្ថយការចម្លងជំងឺ COVID-19 ពីមនុស្សម្នាក់ទៅម្នាក់ទៀតបានយ៉ាងច្រើន ដោយជួយសង្គ្រោះអាយុជីវិត និងជួយឱ្យសេដ្ឋកិច្ចបន្តដំណើរការដោយសុវត្ថិភាព និងប្រកបដោយភាពឆ្លាតវៃ។ យុទ្ធសាស្ត្របង្ការច្រើនដំណាក់កាលដូចជា ការចាក់វ៉ាក់សាំងទាន់សភាពការណ៍ និងការពាក់ម៉ាស់អាចជួយបង្ការជំងឺធ្ងន់ធ្ងរ ព្រមទាំងកាត់បន្ថយការរាំងស្ទះដែលអាចកើតមានលើប្រព័ន្ធថែទាំសុខភាព ជាពិសេសនៅពេលដែលការឆ្លងមានកម្រិតខ្ពស់។

យោងតាម Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) ម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើមមួយចំនួនផ្តល់ការការពារកម្រិតខ្ពស់ជាងមួយចំនួនទៀត ហើយមួយចំនួនពិបាកនឹងទ្រាំឬពាក់ឱ្យបានជាប់លាប់ជាងមួយចំនួនទៀត។ អ្វីដែលសំខាន់បំផុតគឺត្រូវពាក់ម៉ាស់ដែលតឹងណែនល្អ ឬប្រដាប់ជំនួយការដកដង្ហើមឱ្យបានត្រឹមត្រូវ ដែលមានផាសុកភាពសម្រាប់អ្នក និងផ្តល់ការការពារបានល្អ។ ព័ត៌មានបន្ថែមមាននៅលើគេហទំព័ររបស់ CDC អំពីប្រភេទម៉ាស់ និងប្រដាប់ជំនួយការដកដង្ហើម។

ក្បាំងមុខដែលមានរនាំងពីក្រោមអាចប្រើប្រាស់ដោយមនុស្សដែលមានបញ្ហាផ្នែកវេជ្ជសាស្ត្រ ការលូតលាស់ឬ អាកប្បកិរិយាដែលរារាំងមិនឱ្យពួកគេពាក់ម៉ាស់បាន។ ក្បាំងមុខដែលមានរនាំងក្រណាត់ពីក្រោមក៏អាចប្រើបានផងដែរ រួមទាំងប្រើដោយកុមារក្នុងមណ្ឌលថែទាំកុមារ ជំរំថែទាំកុមារនាពេលថ្ងៃ និងមជ្ឈដ្ឋានថ្នាក់មត្តេយ្យដល់ថ្នាក់ទី12 ប្រសិនបើមិនអាចទ្រាំនឹងម៉ាស់ដែលតឹងណែនល្អបានទេ។ សូមមើលការណែនាំរបស់ Department of Health (DOH, ក្រសួងសុខាភិបាល) ដើម្បីជ្រាបព័ត៌មានអំពីការពាក់ម៉ាស់សម្រាប់សាលារៀនថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 មណ្ឌលថែទាំកុមារ ថ្នាក់មុនមត្តេយ្យ ថ្នាក់អភិវឌ្ឍយុវជន និងកម្មវិធីជំរំថែទាំកុមារនាពេលថ្ងៃ (ខ្មែរ)។ បន្ថែមពីនេះ សូមមើលផ្នែករបស់ CDC អំពីការពិចារណាសម្រាប់ក្រុមមនុស្សជាក់លាក់ ដើម្បីជ្រាបព័ត៌មានបន្ថែម។ DOH មិនណែនាំឱ្យប្រើម៉ាស់ដែលមានសន្ទះឬរន្ធខ្យល់ដង្ហើមចេញ ឬកូនកន្សែងនិងស្រោមការពារដែលមានតែមួយស្រទាប់នោះទេ។

នៅកន្លែងធ្វើការ អាចតម្រូវឱ្យប្រើប្រភេទម៉ាស់ ឬប្រដាប់ជំនួយការដកដង្ហើមជាក់លាក់។ ប្រដាប់ជំនួយការដកដង្ហើមដែលមានសន្ទះខ្យល់ដង្ហើមចេញ អាចប្រើស្របតាមការណែនាំដែលចេញផ្សាយដោយ Washington State Department of Health (DOH, ក្រសួងសុខាភិបាលនៃរដ្ឋវ៉ាស៊ីនតោន) និង Washington State Department of Labor & Industries (L&I, ក្រសួងការងារនិងឧស្សាហកម្មនៃរដ្ឋវ៉ាស៊ីនតោន) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។

សូមចូលមើលគេហទំព័ររបស់ DOH អំពីម៉ាស់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីមើលបញ្ជីសំណួរដែលចោទសួរជាញឹកញាប់អំពីម៉ាស់។

## សេចក្តីបង្គាប់ និងបទបញ្ជាសុខភាពបច្ចុប្បន្ន

បទបញ្ជាសាធារណៈបច្ចុប្បន្នខាងក្រោមតម្រូវឱ្យប្រជាជនពាក់ម៉ាស់ក្នុងមជ្ឈដ្ឋានមួយចំនួន រួមមាន៖

- មជ្ឈដ្ឋានថែទាំសុខភាព
- មណ្ឌលកែប្រែ និងពន្ធនាគារ (ពន្ធនាគារសម្រាប់មនុស្សពេញវ័យ)
- មធ្យោបាយធ្វើដំណើរសាធារណៈ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)

### បទបញ្ជារបស់ Department of Health នៃរដ្ឋវ៉ាស៊ីនតោន

Secretary of Health Mask Order (សេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) តម្រូវឱ្យប្រជាជនក្នុងរដ្ឋវ៉ាស៊ីនតោនពាក់ម៉ាស់ក្នុងមជ្ឈដ្ឋានថែទាំសុខភាព ក៏ដូចជាមណ្ឌលនិងពន្ធនាគារសម្រាប់មនុស្សពេញវ័យ ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំង ហើយមានករណីលើកលែងមានកម្រិត។ មនុស្សមានទំនួលខុសត្រូវរៀងៗខ្លួនក្នុងការអនុវត្តតាមបទបញ្ជានេះ ប៉ុន្តែអាជីវកម្មក៏មានការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់នេះទៅលើបុគ្គលិក និងអតិថិជនរបស់ពួកគេដែរ។ សូមមើលបទបញ្ជាខាងក្រោម ដើម្បីជ្រាបព័ត៌មានបន្ថែម។

### បទបញ្ជាសហព័ន្ធ

លក្ខខណ្ឌតម្រូវសម្រាប់មធ្យោបាយធ្វើដំណើរសាធារណៈមាននៅក្នុង Centers for Disease Control and Prevention order (បទបញ្ជារបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ បទបញ្ជានេះតម្រូវឱ្យពាក់ម៉ាស់ដោយអ្នកដំណើរនៅលើគ្រប់មធ្យោបាយធ្វើដំណើរសាធារណៈ និងនៅក្នុងមជ្ឈមណ្ឌលដឹកជញ្ជូនទាំងអស់ រួមមានជាអាទ៍យន្តហោះ នាវា ស្រឡាង រថភ្លើង រថភ្លើងក្រោមដី រថយន្តក្រុង តាក់ស៊ី និងការធ្វើដំណើររួមគ្នា។ អ្នកបញ្ជាមធ្យោបាយធ្វើដំណើរសាធារណៈត្រូវតែតម្រូវឱ្យអ្នកដំណើរទាំងអស់ពាក់ម៉ាស់ នៅពេលឡើងជិះ ចុះចេញ និងក្នុងពេលធ្វើដំណើរ។ ព័ត៌មានបន្ថែមមាននៅលើគេហទំព័ររបស់ CDC អំពីសិទ្ធិអំណាចផ្លូវច្បាប់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។

CDC មិនតម្រូវឱ្យប្រជាជនពាក់ម៉ាស់នៅលើរថយន្តក្រុង ឬរថយន្តដឹកសិស្សដែលធ្វើប្រតិបត្តិការដោយកម្មវិធីថែទាំ/អប់រំកុមារកម្រិតដំបូង ឬប្រព័ន្ធសាលារៀនថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 របស់រដ្ឋ ឬឯកជនទេ។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន កម្មវិធីអប់រំកុមារកម្រិតដំបូង និងប្រព័ន្ធសាលារៀនអាចសម្រេចចិត្តថាតម្រូវឱ្យមនុស្សពាក់ម៉ាស់នៅលើរថយន្តក្រុង ឬរថយន្តដឹកសិស្ស ឬអត់។ សូមមើលលក្ខខណ្ឌតម្រូវ និងការណែនាំដើម្បីកាត់បន្ថយការចម្លងជំងឺ COVID-19 នៅសាលារៀនថ្នាក់មត្តេយ្យដល់ថ្នាក់ទី 12 មណ្ឌលថែទាំកុមារ ថ្នាក់មុនមត្តេយ្យ ថ្នាក់អភិវឌ្ឍយុវជន និងកម្មវិធីជំរំថែទាំកុមារនាពេលថ្ងៃរបស់ DOH (ខ្មែរ) ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីការធ្វើដំណើរតាមរថយន្តក្រុង។

### សេចក្តីប្រកាសរបស់អភិបាលរដ្ឋវ៉ាស៊ីនតោន

ព័ត៌មានអំពីទំនួលខុសត្រូវ និងការរំពឹងទុកសម្រាប់អាជីវកម្មដែលពាក់ព័ន្ធនឹងអតិថិជន និងបុគ្គលិកត្រូវបានចុះក្នុង សេចក្តីប្រកាសលេខ 20-25.19 ស្តីពីរដ្ឋវ៉ាស៊ីនតោនត្រៀមខ្លួនសម្រាប់ COVID-19 (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងសេចក្តីប្រកាសលេខ 21-08 – បុគ្គលិកមានសុវត្ថិភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។

### សេចក្តីប្រកាសរបស់ក្រសួងការងារនិងឧស្សាហកម្ម និងរបស់អភិបាលរដ្ឋ

ទោះបីជាមិនតម្រូវឱ្យពាក់ម៉ាស់ក្នុងកន្លែងធ្វើការភាគច្រើនតាមសេចក្តីប្រកាសរបស់អភិបាលរដ្ឋខាងលើ ក៏អាជីវកម្មឯកជននៅតែអាចតម្រូវឱ្យពាក់ម៉ាស់បានដែរ ប្រសិនបើពួកគេសម្រេចចិត្តបែបនេះ។ សូមគោរព វិធានតាមទីតាំង។ បន្ថែមពីនេះ តាមសេចក្តីប្រកាសរបស់អភិបាលរដ្ឋស្តីពីបុគ្គលិកមានសុវត្ថិភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) បុគ្គលិកមួយចំនួនដែលខ្លួនឯងផ្ទាល់មានហានិភ័យសុខភាពជាក់លាក់ ឬរស់នៅជាមួយមនុស្សមានហានិភ័យដែលអាចកើតជំងឺ COVID-19 ធ្ងន់ធ្ងរ ប្រហែលជានៅតែត្រូវ ឬអាចសម្រេចចិត្តពាក់ម៉ាស់បាន។ បុគ្គលិកមានសិទ្ធិពាក់ម៉ាស់ដើម្បីការពារខ្លួន គ្រួសារ និងសហគមន៍

របស់ខ្លួន។ នៅឆ្នាំ 2021 អង្គនីតិបញ្ញត្តិបានអនុម័តលើសេចក្តីព្រាងច្បាប់ថ្មីរបស់ព្រឹទ្ធសភាលេខ 5254 ដែលការពារសិទ្ធិរបស់បុគ្គលិកក្នុងការពាក់ម៉ាស់អំឡុងពេលមានអាសន្នផ្នែកសុខភាពសាធារណៈ ហើយឥឡូវការការពារនេះត្រូវបានបង្កើតជាច្បាប់ Revised Code of Washington (RCW, ច្បាប់រដ្ឋវ៉ាស៊ីនតោនដែលបានកែប្រែ) លេខ 49.17.485 (ភាសាអង់គ្លេសប៉ុណ្ណោះ)។ សូមមើលលក្ខខណ្ឌតម្រូវ និងការណែនាំសម្រាប់បង្ការជំងឺ COVID-19 (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងសំណួរទូទៅអំពីជំងឺ COVID-19 ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវអំពីម៉ាស់ និងរបាំងមុខសម្រាប់បុគ្គលិករបស់ L&I (ភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីកន្លែងធ្វើការ។

### អង្គភាព និងមន្ត្រីសុខាភិបាលសាធារណៈក្នុងមូលដ្ឋាន

មន្ត្រីសុខាភិបាលក្នុងមូលដ្ឋានមានសិទ្ធិដាក់បទបញ្ជាសុខភាពដើម្បីគ្រប់គ្រងនិងបង្ការការឆ្លងរាលដាលនៃជំងឺនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បទបញ្ជាទាំងនេះអាចមានភាពតឹងរ៉ឹងជាងបទបញ្ជាទូទាំងរដ្ឋ ប៉ុន្តែមិនអាចតឹងរ៉ឹងតិចជាងនេះទេ។ សូមសាកសួរមន្ត្រីមានសមត្ថកិច្ចផ្នែកសុខាភិបាលក្នុងមូលដ្ឋាន (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងអនុវត្តតាមបទបញ្ជាសុខភាពទាំងអស់ដែលមានសម្រាប់តំបន់នោះ។

## ការណែនាំ

ព័ត៌មានខាងលើបញ្ជាក់ពីលក្ខខណ្ឌតម្រូវដែលនៅមានសម្រាប់ការប្រើម៉ាស់ក្នុងមជ្ឈដ្ឋានជាក់លាក់នៅពេលនេះ រីឯព័ត៌មានខាងក្រោមបញ្ជាក់អំពីការណែនាំផ្នែកសុខភាពសាធារណៈទូទៅសម្រាប់ពិចារណា។

### ការណែនាំអំពីការពាក់ម៉ាស់សម្រាប់មជ្ឈដ្ឋានប្រមូលផ្តុំដែលមិនថែទាំសុខភាព

ការប្រើម៉ាស់ក្នុងអគារត្រូវបានណែនាំ នៅពេលដែលអាចធ្វើទៅបានក្នុងមជ្ឈដ្ឋានខាងក្រោម។ សូមមើលការណែនាំតាមផ្នែកខាងក្រោម។

- គេហទំព័រអ្នកផ្តល់សេវាគ្មានផ្ទះសម្បែង (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- មជ្ឈដ្ឋានដែនសមុទ្រពាណិជ្ជកម្ម (ជាភាសាអង់គ្លេសប៉ុណ្ណោះ) (ឧ. នាវាដឹកអាហារសមុទ្របែបពាណិជ្ជកម្ម (ជាភាសាអង់គ្លេសប៉ុណ្ណោះ) នាវាដឹកទំនិញ នាវាទេសចរណ៍)
- មជ្ឈដ្ឋានការងារមានមនុស្សច្រើន (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដែលការរក្សាគម្លាតរាងកាយមិនអាចធ្វើទៅបានដោយសារលក្ខណៈនៃកន្លែងធ្វើការដូចជា ឃ្លាំង រោងចក្រ និងរោងចក្រកែច្នៃសាច់ និងការវេចខ្ចប់អាហារ
- កន្លែងរស់នៅរួមគ្នាក្នុងទីតាំងរស់នៅប្រមូលផ្តុំ (លើកលែងបន្ទប់គេង) រួមទាំងទីតាំងដោះលែងឱ្យធ្វើការ លំនៅដ្ឋានបណ្តោះអាសន្ន មន្ទីរឃុំឃាំងឬស្ថានីតិសម្បទាអនីតិជន និងលំនៅដ្ឋានកម្មករបណ្តោះអាសន្ន
- ក្នុងអគារនៃមជ្ឈដ្ឋានដែលមានមនុស្សជាប់ពន្ធនាគារសម្រាប់មនុស្សពេញវ័យ មណ្ឌលស្តារនីតិសម្បទាអនីតិជន ឬមន្ទីរឃុំឃាំងអនីតិជន (ឧ. បន្ទប់តុលាការ)។

បុគ្គលដែលរស់នៅ ឬធ្វើការក្នុងមជ្ឈដ្ឋានខាងលើគួរតែអនុវត្តតាមការណែនាំដូចគ្នាទៅនឹងសាធារណជនទូទៅដែរ នៅពេលមិនស្ថិតក្នុងមជ្ឈដ្ឋានទាំងនេះ (ឧ. នៅពេលចេញក្រៅក្នុងសហគមន៍)។ អាជ្ញាធរសុខភាពសាធារណៈអាចតម្រូវឱ្យប្រើម៉ាស់ក្នុងកាលៈទេសៈមួយចំនួន ដូចជាពេលផ្ទុះជំងឺជាដើម។

កន្លែងមិនថែទាំសុខភាពដែលមានមនុស្សប្រមូលផ្តុំ (ដូចជាអាជីវកម្ម និងអង្គការ) អាចតម្រូវឱ្យពាក់ម៉ាស់ក្នុងទីតាំងរបស់ខ្លួន។ កន្លែងទាំងនេះគួរតែពិចារណាលើកត្តាទាំងអស់ខាងក្រោម នៅពេលសម្រេចចិត្តថាតម្រូវឱ្យពាក់ម៉ាស់ក្នុងមជ្ឈដ្ឋានរបស់ខ្លួនឬអត់៖

- ភាពងាយរងគ្រោះរបស់មនុស្សក្នុងមជ្ឈដ្ឋាន
    - បុគ្គលដែលមិនបានចាក់វ៉ាក់សាំងជំងឺ COVID-19 ទាន់សភាពការណ៍ ងាយឆ្លងជំងឺ COVID-19 ជាង និងងាយវិវឌ្ឍជាជំងឺធ្ងន់ធ្ងរជាង

  - បុគ្គលដែលមាន[បញ្ហាសុខភាពជាក់លាក់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] មានហានិភ័យខ្ពស់ជាងក្នុងការកើតជំងឺ COVID-19 ធ្ងន់ធ្ងរ
- គុណភាពប្រព័ន្ធខ្យល់ចេញចូលក្នុងមជ្ឈដ្ឋាន - សូមមើល[ប្រព័ន្ធខ្យល់ចេញចូល និងគុណភាពខ្យល់សម្រាប់កាត់បន្ថយការចម្លងជំងឺ COVID-19 (wa.gov) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] និង[ប្រព័ន្ធខ្យល់ចេញចូលក្នុងអគារ | CDC] ដើម្បីជ្រាបព័ត៌មាន និងជម្រើសប្រព័ន្ធខ្យល់ចេញចូល រួមទាំងកន្លែងដែលមាននិងគ្មានប្រព័ន្ធកម្តៅ ខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់
- លទ្ធភាពរក្សាគម្លាតរាងកាយរបស់មនុស្សក្នុងមជ្ឈដ្ឋាន
- ការផ្ទុះជំងឺ COVID-19 ដែលគេសង្ស័យ ឬមានការបញ្ជាក់នៅក្នុងមជ្ឈដ្ឋាន – ណែនាំយ៉ាងខ្លាំងឱ្យប្រើម៉ាស់ក្នុងអគារ នៅពេលមានការផ្ទុះជំងឺក្នុងមជ្ឈដ្ឋានប្រមូលផ្តុំដែលមិនថែទាំសុខភាព
- នៅពេលជំងឺក្នុងសហគមន៍មានកម្រិតខ្ពស់ នោះ CDC និង DOH ណែនាំឱ្យមនុស្សគ្រប់រូបពាក់ម៉ាស់ក្នុងអគារ ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំង។ សូមមើល[កម្រិតជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC]

កន្លែងទាំងនេះមិនគួរបង្អាក់ទឹកចិត្តបុគ្គលនានាមិនឱ្យពាក់ម៉ាស់ទេ ប្រសិនបើពួកគេសម្រេចចិត្តពាក់ម៉ាស់។ សូមមើលការណែនាំអំពីការពាក់ម៉ាស់ និងការពិចារណាផ្អែកលើហានិភ័យសម្រាប់បុគ្គលនៅខាងក្រោម។

## ការណែនាំអំពីម៉ាស់សម្រាប់បុគ្គល

បុគ្គលមានរោគសញ្ញា ធ្វើតេស្តឃើញវិជ្ជមាន ឬប៉ះពាល់នឹងនរណាម្នាក់ដែលមានផ្ទុកជំងឺ COVID-19 គួរតែពាក់ម៉ាស់ស្របតាម[អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមានជំងឺ COVID-19 (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] [អ្វីដែលត្រូវធ្វើ ប្រសិនបើអ្នកប្រហែលជាបានប៉ះពាល់នឹងនរណាម្នាក់ដែលមានផ្ទុកជំងឺ COVID-19 (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] និង[មែកធាងសម្រេចចិត្តលើរោគសញ្ញាជំងឺ COVID-19]។ បុគ្គលនានាត្រូវតែពាក់ម៉ាស់ ប្រសិនបើមានការតម្រូវសម្រាប់មជ្ឈដ្ឋានដែលពួកគេស្ថិតនៅ។ សូមមើលផ្នែក[សេចក្តីបង្គាប់ និងបទបញ្ជាសុខភាពបច្ចុប្បន្ន] ដើម្បីជ្រាបពីលក្ខខណ្ឌតម្រូវ។

ទោះបីជាមិនត្រូវនឹងកាលៈទេសៈខាងលើក៏ដោយ ក៏ប្រជាជនអាចពាក់ម៉ាស់តាមចំណូលចិត្តផ្ទាល់ខ្លួនបានដែរ ប្រសិនបើដឹងពីកម្រិតហានិភ័យផ្ទាល់ខ្លួន ឬក្នុងសហគមន៍។ បុគ្គលនានាគួរតែពិចារណាលើកត្តាខាងក្រោម នៅពេលសម្រេចចិត្តថាត្រូវពាក់ម៉ាស់ឬអត់៖

- ស្ថានភាពចាក់វ៉ាក់សាំងរបស់បុគ្គល និងស្ថានភាពចាក់វ៉ាក់សាំងរបស់គ្រួសារ មិត្តភ័ក្តិ និងអ្នកផ្សេងទៀតនៅជុំវិញពួកគេ - បុគ្គលដែលមិនបានចាក់វ៉ាក់សាំងជំងឺ COVID-19 [ទាន់សភាពការណ៍] ងាយឆ្លងជំងឺ COVID-19 ជាង និងងាយវិវឌ្ឍជាជំងឺធ្ងន់ធ្ងរជាង
- [បញ្ហាសុខភាព] របស់បុគ្គល និងបញ្ហាសុខភាពរបស់គ្រួសារ មិត្តភ័ក្តិ និងអ្នកផ្សេងទៀតនៅជុំវិញពួកគេ ដែលធ្វើឱ្យមានហានិភ័យកាន់តែខ្ពស់ក្នុងការកើតជំងឺ COVID-19 ធ្ងន់ធ្ងរ
- មជ្ឈដ្ឋានដែលអ្នកស្ថិតនៅមានលក្ខណៈបែបណា (ឧ. មនុស្សកកកុញ ខ្យល់ចេញចូលមិនល្អ)
- នៅពេលជំងឺក្នុងសហគមន៍មានកម្រិតខ្ពស់ នោះ CDC និង DOH ណែនាំឱ្យមនុស្សគ្រប់រូបពាក់ម៉ាស់ក្នុងអគារ ដោយមិនគិតពីស្ថានភាពចាក់វ៉ាក់សាំង។ សូមមើល[កម្រិតជំងឺ COVID-19 ក្នុងសហគមន៍របស់ CDC]

## ព័ត៌មាន និងធនធានច្រើនទៀតអំពីជំងឺ COVID–19

បន្តតាមដានព័ត៌មានថ្មីៗអំពី[ស្ថានភាពជំងឺ COVID-19 បច្ចុប្បន្ននៅរដ្ឋវ៉ាស៊ីនតោន (ខ្មែរ)], [សេចក្តីប្រកាសរបស់លោកអភិបាល Inslee (ជាភាសាអង់គ្លេសប៉ុណ្ណោះ)], [រោគសញ្ញា (ជាភាសាអង់គ្លេសប៉ុណ្ណោះ)], [របៀបដែលវារីករាលដាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] និង[របៀបនិងពេលដែលមនុស្សគួរតែធ្វើតេស្ត (ជាភាសាអង់គ្លេសប៉ុណ្ណោះ)]។ សូមមើល[សំណួរចោទសួរជាញឹកញាប់ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)] របស់យើងសម្រាប់ព័ត៌មានបន្ថែម។

ពូជសាសន៍/ជនជាតិ ឬសញ្ជាតិរបស់មនុស្សម្នាក់ៗតែមួយមុខ មិនធ្វើឲ្យពួកគេប្រឈមនឹងហានិភ័យកាន់តែខ្ពស់ដែលអាចកើតជំងឺ COVID-19 ឡើយ។ ប៉ុន្តែទិន្នន័យបង្ហាញថាសហគមន៍ជនជាតិស្បែកខ្មៅកំពុងរងផលប៉ះពាល់យ៉ាងច្រើនពីជំងឺ COVID-19 នេះដោយសារតែផលប៉ះពាល់នៃការរើសអើងជាតិសាសន៍ និងជាពិសេសការរើសអើងជាតិសាសន៍ជារចនាសម្ព័ន្ធ ដែលទុកឲ្យក្រុមជាតិសាសន៍មួយចំនួនមានឱកាសតិចតួចក្នុងការការពារខ្លួននិងសហគមន៍របស់ពួកគេ។ ពាក្យបង្កាច់បង្ខូចគ្នានឹងមិនជួយដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺនោះទេ (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។ ចែករំលែកព័ត៌មានត្រឹមត្រូវជាមួយអ្នកដទៃដើម្បីទប់ស្កាត់ពាក្យចចាមអារ៉ាម និងព័ត៌មានមិនពិតកុំឲ្យរីករាលដាលបាន។

- ការផ្ទុះវីរុសក្សរ៉ូណាប្រភេទថ្មី (COVID-19) ពី Department of Health នៃរដ្ឋវ៉ាស៊ីនតោន ឆ្នាំ 2019 (ខ្មែរ)
- ការឆ្លើយតបចំពោះវីរុសក្សរ៉ូណា (COVID-19) របស់រដ្ឋវ៉ាស៊ីនតោន (ខ្មែរ)
- ស្វែងរកក្រសួងសុខាភិបាលក្នុងតំបន់ ឬមណ្ឌលរបស់អ្នក (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- វីរុសក្សរ៉ូណា (COVID-19) របស់ CDC (ជាភាសាអង់គ្លេសប៉ុណ្ណោះ)
- របៀបធ្វើម៉ាស់ងាយស្រួលប្រើ សមស្របសម្រាប់បុគ្គលស្តាប់មិនឮ (HSDC) (ជាភាសាអង់គ្លេសប៉ុណ្ណោះ)

មានសំណួរបន្ថែមមែនទេ? សូមហៅមកខ្សែទូរសព្ទបន្ទាន់ផ្នែកព័ត៌មានអំពីជំងឺ COVID-19 របស់យើង៖ 1–800–525–0127 ថ្ងៃចន្ទពីម៉ោង 6 ព្រឹកដល់ម៉ោង 10 យប់ ថ្ងៃអង្គារដល់ថ្ងៃអាទិត្យ និងថ្ងៃឈប់សម្រាករបស់រដ្ឋដែលត្រូវបានលើកថ្ងៃ (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ចាប់ពីម៉ោង 6 ព្រឹកដល់ម៉ោង 6 ល្ងាច។ សម្រាប់សេវាកម្មបកប្រែភាសាផ្ទាល់មាត់ សូមចុចសញ្ញា # នៅពេលដែលមានអ្នកលើកទូរសព្ទ ហើយប្រាប់ភាសារបស់អ្នក។ សម្រាប់សំណួរអំពីសុខភាពផ្ទាល់ខ្លួន ការធ្វើតេស្តជំងឺ COVID-19 ឬលទ្ធផលធ្វើតេស្តរបស់អ្នក សូមទាក់ទងទៅអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក។

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

## ឯកសារបន្ថែមខាងចុង A៖ សទ្ទានុក្រម

**មជ្ឈដ្ឋានថែទាំសុខភាព**

យោងតាម Secretary of Health's Mask Order (សេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល) (ជាភាសាអង់គ្លេសប៉ុណ្ណោះ) មជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែងគឺជាមជ្ឈដ្ឋានឯកជនឬសាធារណៈទាំងឡាយដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាពដោយផ្ទាល់ដល់ប្រជាជន ដោយមានករណីលើកលែងមួយចំនួន។ ប្រសិនបើស្ថិតក្នុងទីតាំងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដូចជាមន្ទីរពេទ្យជាដើម នោះទីតាំងទាំងមូលគឺជាមជ្ឈដ្ឋានថែទាំសុខភាព ឬមជ្ឈដ្ឋានថែទាំរយៈពេលវែង ហើយត្រូវតែពាក់របាំងមុខទូទាំងទីតាំងនេះ ដោយអនុលោមតាមករណីលើកលែងក្នុងបទបញ្ជាស្តីពីរបាំងមុខ។ ប្រសិនបើស្ថិតក្នុងទីតាំងដែលប្រើជាចម្បងសម្រាប់គោលបំណងផ្សេងទៀត ដូចជាឱសថស្ថាននៅក្នុងហាងលក់គ្រឿងទេស ឬការិយាល័យគិលានុបដ្ឋាកប្រចាំសាលារៀនជាដើម នោះមជ្ឈដ្ឋានថែទាំសុខភាព ឬមជ្ឈដ្ឋានថែទាំរយៈពេលវែងរាប់បញ្ចូលតែកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាពប៉ុណ្ណោះ ប៉ុន្តែមិនរាប់បញ្ចូលកន្លែងផ្សេងទៀតនៃទីតាំងនេះទេ។ របាំងមុខត្រូវតែពាក់នៅកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដោយអនុលោមតាមករណីលើកលែងក្នុងបទបញ្ជាស្តីពីរបាំងមុខ។ លុះត្រាតែមិនរាប់បញ្ចូលខាងក្រោម អ្នកផ្តល់សេវាថែទាំសុខភាពរួមបញ្ចូលបុគ្គលដែលមានឯកសារបញ្ជាក់ក្នុងបញ្ជីលក្ខខណ្ឌតម្រូវអំពីការផ្តល់ឯកសារបញ្ជាក់ជំនាញថែទាំសុខភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ក៏ដូចជាបុគ្គលដែលត្រូវបានអនុញ្ញាតដោយច្បាប់ឱ្យផ្តល់សេវាថែទាំសុខភាពដោយមិនចាំបាច់មានឯកសារបញ្ជាក់។ **បុគ្គលិក និងភ្ញៀវទាំងអស់ បន្ថែមលើអ្នកជំនាញថែទាំសុខភាព ត្រូវបានតម្រូវឱ្យពាក់ម៉ាស់ពេលស្ថិតនៅក្នុងអគារនៃមជ្ឈដ្ឋានថែទាំសុខភាព។**

ខាងក្រោមនេះគឺជាបញ្ជីទូទៅនៃមជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែង៖

- ទីតាំងថែទាំកម្រិតធ្ងន់រួមមានជាអាទិ៍ មន្ទីរពេទ្យនានា។
- ទីតាំងថែទាំកម្រិតធ្ងន់រយៈពេលវែង។
- ទីតាំងស្តារនីតិសម្បទាអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។
- ទីតាំងថែទាំសុខភាពឥរិយាបថអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរួមមានជាអាទិ៍ ទីតាំងវាយតម្លៃនិងព្យាបាល ទីតាំងដែលអាចរស់នៅក្នុងពេលព្យាបាល ទីតាំងបន្សាបជាតិពុលដែលមានសុវត្ថិភាព។
- ទីតាំងដែលអាចរស់នៅក្នុងពេលថែទាំរយៈពេលវែងរួមមានជាអាទិ៍ មណ្ឌលថែទាំជនចាស់ជរា ទីតាំងរស់នៅដែលមានជំនួយ មណ្ឌលថែទាំមនុស្សពេញវ័យជាក្រុម មជ្ឈដ្ឋានផ្តល់ជំនួយនិងសេវារស់នៅជាសហគមន៍ដែលមានលិខិតបញ្ជាក់ និងទីតាំងផ្តល់សេវាធ្វើឱ្យប្រសើរឡើង។
- គ្លីនិកចល័ត ឬយានជំនិះផ្សេងទៀតដែលផ្តល់ការថែទាំសុខភាព។
- ទីតាំងផ្តល់ការព្យាបាលមិនសម្រាកក្នុងមន្ទីរពេទ្យរួមមានជាអាទិ៍ មជ្ឈមណ្ឌលលាងឈាម ការិយាល័យគ្រូពេទ្យ និងទីតាំងថែទាំសុខភាពឥរិយាបថ (រួមមានការិយាល័យគ្រូពេទ្យពោគសតិ អ្នកប្រឹក្សាសុខភាពផ្លូវចិត្ត និងអ្នកជំនាញផ្នែកជំងឺដោយសារការប្រើប្រាស់សារធាតុញៀន)។
- ទីតាំងទន្តពេទ្យ និងឯកទេសផ្នែកទន្តពេទ្យ។
- ទីតាំងចក្ខុសាស្រ្ត និងចក្ខុរោគសាស្រ្ត។
- ឱសថស្ថាន (មិនរួមបញ្ចូលកន្លែងលក់រាយ)។
- ការិយាល័យព្យាបាលដោយម៉ាស្សា (រួមបញ្ចូលកន្លែងដែលបានរៀបចំសម្រាប់ផ្តល់ការម៉ាស្សាក្នុងមជ្ឈដ្ឋានមិនថែទាំសុខភាព ដូចជាមជ្ឈមណ្ឌលហាត់ប្រាណ/សុខុមាលភាព និងស្ប៉ាជាដើម)។
- ការិយាល័យចាប់សរសៃ។
- មជ្ឈមណ្ឌលសម្រាលកូនដាច់ដោយឡែក និងសេវាពេទ្យឆ្មប។
- ទីតាំងនៅដាច់ដោយឡែក និង/ឬធ្វើចត្តាឡីស័ក។
- ទីតាំងវះកាត់មិនសម្រាកក្នុងមន្ទីរពេទ្យ។

- មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់។
- មជ្ឈមណ្ឌលថែទាំក្នុងដំណាក់កាលចុងក្រោយ និង
- មជ្ឈដ្ឋានដែលផ្តល់សេវាថែទាំសុខភាពនៅផ្ទះ ថែទាំនៅផ្ទះ ថែទាំផ្ទាល់ខ្លួន ឬថែទាំក្នុងដំណាក់កាលចុងក្រោយដោយអ្នកផ្តល់សេវាដែលគិតថ្លៃ។

មជ្ឈដ្ឋានថែទាំសុខភាព និងមជ្ឈដ្ឋានថែទាំរយៈពេលវែងមិនរាប់បញ្ចូលៈ

- មជ្ឈដ្ឋានដែលព្រឹត្តិការណ៍កីឡា និងទស្សនិកជន ឬព្រឹត្តិការណ៍ប្រមូលផ្តុំមនុស្សផ្សេងទៀតប្រព្រឹត្តទៅ (រួមទាំងនៅពេលដែលគ្រូបង្វឹកអត្តពលកម្មដែលមានឯកសារបញ្ជាក់កំពុងផ្តល់ការថែទាំដល់កីឡាករ) ក្រៅពីកន្លែងដែលប្រើជាចម្បងសម្រាប់ផ្តល់សេវាថែទាំសុខភាព ដូចជាកន្លែងដែលរៀបចំសម្រាប់សង្គ្រោះបឋម (ដែលជាមជ្ឈដ្ឋានថែទាំសុខភាព)។
- មណ្ឌលកូនចិញ្ចឹមដែលចេញអាជ្ញាបណ្ណដោយ Department of Children, Youth & Families (DCYF, ក្រសួងកុមារ យុវជន និងគ្រួសារ) ដែលមិនផ្តល់សេវាថែទាំសុខភាពជាចម្បង។
- ទីតាំងស្រាវជ្រាវដែលមិនផ្តល់សេវាថែទាំសុខភាពដល់ប្រជាជន។
- មជ្ឈដ្ឋានថែទាំសុខភាពសត្វ។
- ទីភ្នាក់ងារគ្រប់គ្រងសត្វ។
- អង្គការសង្គមមនុស្សធម៌មិនស្វែងរកប្រាក់ចំណេញ និង
- ហាងលក់កញ្ចាវាយ រួមទាំងហាងដែលអ្នកប្រឹក្សាវេជ្ជសាស្ត្រអំពីកញ្ឆាផ្តល់សេវាកម្ម។

ប្រសិនបើទីតាំងថែទាំសុខភាពតម្រូវឱ្យពាក់ម៉ាស់ក្រៅអគារ អ្នកត្រូវតែប្រកាន់ខ្ជាប់តាមវិធាននៃអាជីវកម្មពួកគេ។ សូមមើលព័ត៌មានអំពី "វិធានតាមទីតាំង" ខាងលើ ដើម្បីជ្រាបព័ត៌មានបន្ថែម។ សូមចូលមើលទំព័រអំពីការបង្ការការចម្លងជំងឺ COVID-19 ក្នុងមជ្ឈដ្ឋានថែទាំសុខភាព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ដើម្បីមើលការណែនាំលម្អិត រួមទាំងការណែនាំអំពីការគ្រប់គ្រងប្រភព (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងការណែនាំអំពីការទៅជួបគ្រូពេទ្យសម្រាប់ទីតាំងថែទាំសុខភាពមួយចំនួន។

**វិធានតាមទីតាំង**

អាជីវកម្ម អង្គការ គ្រឹះស្ថាន និងទីតាំងនានាមានសិទ្ធិក្នុងការបង្កើតវិធានផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ការពាក់ម៉ាស់នៅក្នុងគ្រឹះស្ថានឬទីតាំងរបស់ពួកគេ។ អាជីវកម្មនានាត្រូវបានតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវទាំងអស់ក្នុងសេចក្តីណែនាំរបស់ L&I (ជាភាសាអង់គ្លេសប៉ុណ្ណោះ) និងអាចសម្រេចចិត្តតម្រូវឱ្យពាក់ម៉ាស់ក្នុងមជ្ឈដ្ឋាននានា (ឧ. ក្រៅអាគារ) ដើម្បីឱ្យមានការការពារខ្ពស់ជាងសេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ)។

មន្ត្រីសុខាភិបាលសាធារណៈក្នុងមូលដ្ឋានក៏អាចដាក់ចេញនូវសេចក្តីបង្គាប់ឱ្យពាក់ម៉ាស់ការពារបន្ថែម ដើម្បីកាត់បន្ថយការចម្លងជំងឺក្នុងសហគមន៍ផងដែរ។ វិធានទាំងនេះអាចមានការការពារខ្ពស់ជាងសេចក្តីបង្គាប់អំពីម៉ាស់របស់លេខាធិការក្រសួងសុខាភិបាល (ជាភាសាអង់គ្លេសប៉ុណ្ណោះ) ប៉ុន្តែមិនអាចការពារទាបជាងនោះទេ។

បន្ថែមពីនេះ បុគ្គលមួយចំនួនអាចនឹងត្រូវ ឬសម្រេចចិត្តបន្តពាក់ម៉ាស់។ ពួកគេមានសិទ្ធិសម្រេចចិត្តពាក់ម៉ាស់ក្នុងទីសាធារណៈ ទោះបីជានៅពេលដែលសេចក្តីបង្គាប់អំពីការពាក់ម៉ាស់ថ្នាក់មូលដ្ឋានឬរដ្ឋមិនមានសុពលភាពក៏ដោយ។ សូមគោរពតាមការសម្រេចចិត្តពាក់ម៉ាស់របស់ពួកគេដើម្បីការពារខ្លួន គ្រួសារ និងសហគមន៍។ សូមកត់សម្គាល់ថា ប្រសិនបើអ្នកសម្រេចចិត្តពាក់ម៉ាស់ អ្នកអាចនឹងត្រូវបានស្នើឱ្យដោះម៉ាស់ចេញមួយភ្លែតក្នុងស្ថានភាពផ្សេងៗ ដូចជាក្នុងគោលបំណងកំណត់អត្តសញ្ញាណជាដើម។